## វិភាគប្រវត្តិវិទ្យា

# ការបាត់បង់ទឹកដីកម្ពុជាក្រោម

ស្រាវជ្រាវដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី២ វិច្ឆិកា ២០០៥

កោះត្រល់គឺជាទឹកដីមួយចំណិតតូច ឋិតនៅក្នុងកម្ពុជាក្រោមដ៏ធំធេង ដែលជនជាតិយួនបានលួចប្លន់យកទៅ ។ ដូច្នេះ គេមិនអាចធ្វើសេចក្ដីអធិប្បាយ អំពីការបាត់បង់ទឹកដីខ្មែរដ៏សំបើម ដែលធ្លាក់ទៅក្រោមឥទ្ធិពលយួន ដោយគ្រាន់តែរំលឹកពីកោះត្រល់តូចមួយប៉ុណ្ណោះទេ («On ne peut pas parler à part de ce qui n'est pas donné à part») ។ ដូច្នេះខ្មែរយើងទាំងអស់គ្នាក្នុងពេលបច្ចុប្បន្ន ទាំងស្ដេច ទាំងមន្ត្រី ទាំងប្រជានុរាស្ត្រ... គួរតែរំឭកទាមទារពីយួន នូវផែនដីកម្ពុជាក្រោមទាំងមូលមកវិញ... មិនមែននិយាយត្រឹមតែខ្សែបន្ទាត់ ប្រេវីយេ តែប៉ុណ្ណោះទេ ។ បូករួមសេចក្ដីទៅ បើយើងលើកត្រឹមតែកោះត្រល់មកអធិប្បាយ គឺយើងហាក់ដូចជាលើកកញ្ចើរមួយមកបិទបាំងមហាវិនាសកម្ម មហាឧក្រិដ្ឋកម្ម ដែលពួកយួនបានមកសាបព្រួសលើប្រជាជាតិខ្មែរក្រោម ចំនួនក្បែរ៤០០ឆ្នាំមកហើយ ។ ដូចជាមិនគួរឲ្យយួនរួចខ្លួនស្រួលពេកទេដឹង ??

★

«**រជ្ជកាលរបស់ព្រះជ័យជេដ្ឋាទី២**» (គ.ស.១៦១៨-១៦២៨)

យួនចាប់ផ្ដើមលេបត្របាក់ទឹកដីកម្ពុជាក្រោម នៅក្នុងរាជព្រះជ័យជេដ្ឋាទី២ ។

«ដើម្បីទប់ទល់នឹងការរាតត្បាតរបស់សៀម, ព្រះជ័យជេដ្ឋា ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយក្សត្រីវៀតណាមម្នាក់ ក៏បានស្វែងរកជំនួយពីក្រុងវ៉េ (ទីក្រុងវ៉េរបស់យួន ជាអតីត«នគរពិជ័យ»របស់ចាម...«ក្រុងវ៉េ»មានន័យថា «ក្រុងធំ» ដែលជាការបកប្រែសុទ្ធសាធពីពាក្យខ្មែរ ៖ «អង្គរធំ») ។

«រាជវង្សរបស់ស្ដេច«ង្វៀង» ដែលធ្វើការទីតាំងនៅក្រុងវ៉េ ក៏បានរំដោះខ្លួន ពីឥទ្ធិពលរបស់រាជវង្សអធិរាជ «ឡេ» នៅទីក្រុងហាណូយ ។ ពូជស្ដេចង្វៀង ក៏បានមកត្រួតត្រា ក្វាងប៊ិញ, ធួធៀន, ក្វាងណាម និង ក្វាងង៉ៃ ។ ពួកគេបានវាតយកទឹកដីចំប៉ាទាំងមូល ហើយក៏បានតាំងខ្លួនជាអ្នកការពារនគរចំប៉ា «ប៉ាន់ឌូរាំង» (Panduranga) ដែលត្រូវកាត់ភ្ជាប់ជាស្ថាពរជាមួយនឹងដែនដីអណ្ណាម នៅក្នុងឆ្នាំ១៧៩២ ។ ក្នុង

ប្រការនេះ ប្រទេសយួននៃ«រាជវង្សខាងត្បូង» ក៏បានមកទាក់ទងផ្ទាល់ ជាមួយនឹង
អាណាខេត្តខ្មែរនៃដែនដីកូសាំងស៊ីន ។

«នៅឆ្នាំ១៦២៣ អង្គទូតមួយបញ្ជូនពីក្រុងវេ៉ បានមកស្នើសុំដល់ព្រះជ័យជេដ្ឋាទី
២ នូវសេចក្តីអនុញ្ញាតជាផ្លូវការ ដើម្បីបង្កើតសហាគមវៀតណាមនៅក្នុងខេត្តព្រៃន
គរ ( <u>កកន</u> ៖ ខ្មែរហៅថា «ព្រះអង្គរ» ឬ «ព្រះនគរ» ដែលបានក្លាយទៅជា «ព្រេង
គរ» ឬ «ព្រៃនគរ», លុះដល់ចិនយួនស្តាប់មិនច្បាស់ ក៏បកប្រែទៅជា «ព្រៃគរ» ឬ
«សៃគ្កង» ) ។ ក្នុងពេលជាមួយគ្នានោះ ដើម្បីជួយសួយដល់សហាគមជនជាតិយួន
តាមផ្លូវហិរញ្ញវត្ថុ ស្តេចយួនក៏បានស្នើសុំបើកមន្ទីរទារពន្ធទៅលើជំនួញជួញដូរ ដេ-
លធ្វើនៅតំបន់ប្រជុំជន ពោលគឺសៃគ្កងសព្វថ្ងៃ ។ ព្រះរាជាខ្មែរក៏បានទទួលយល់
ព្រម ។ ភ្លាមមួយរំពេជ រាជការក្រុងវេ៉ក៏បានប្រញាប់ប្រញាល់ បញ្ជូនជនជាតិយួនជា
ច្រើន ឲ្យមករស់នៅក្នុងដែនដីកូសាំងស៊ីន ហើយដោយយកលេសថា មកជួយថៅ
ហ្វាយខេត្តខ្មែររៀបចំឲ្យមានសណ្តាប់ធ្នាប់ ក៏បានបញ្ជូនឧត្តមសេនិយយួនម្នាក់មក
បង្កើតទីតាំងបញ្ជាការនៅសៃគ្កងតែម្តង ។

«នៅពេលដែលព្រះជ័យជេដ្ឋាទី២សុគតទៅ តំបន់នោះទាំងមូល ដោយរាប់តាំ
ងពីព្រៃនគរ រហូតដល់អតីតព្រំប្រទល់នគរចំប៉ា ដោយមិនគិតបញ្ចូលតាំងពីក្រុង
ព្រៃនគរ (សៃគ្កង), បារៀ និង កំពប់ស្រកាត្រី (Bien Hoa) ក៏បានធ្លាក់ទៅជាអាណា
និគមយួន» ។ (ដកស្រង់ចេញពី Histoire du Cambodge- Les Interventions du
Vietnam par . Dauphin Meunier- pages 72-73) ។

★

យួនបានចាប់ផ្តើមអង្កៀមទឹកដីកម្ពុជាក្រោម នៅក្នុងរាជ្យជ័យជេដ្ឋាទី២ ។ នៅក្នុ
ងរាជ្យព្រះអង្គដួង មុនពេលបារាំងមកដល់ យួនក៏បានសំរេចជោគជ័យលេបទឹកដី
នេះទាំងមូល ។ សូមអានឯកសារមួយរបស់លោក Adhemard Leclère ៖

«កិច្ចរួមប្រជុំនេះបានប្រព្រឹត្តតៅនៅក្នុងខែធ្នូ១៨៤៥ ។ គេឃើញវត្តមាននៃឧត្ត
មសេនិយសៀម បូឱន និងឧត្តមសេនិយយួនពីរនាក់ ។ ពួកគេបានអនុម័តឲ្យព្រះអ
ង្គដួង ក្លាយទៅជាមហាក្សត្រនៃកម្ពុជា យោងតាមឆន្ទៈនៃរដ្ឋាភិបាលសៀមនិងអ-
ណ្ណាម ។ ពួកគេបានសន្មត់ឲ្យព្រះអង្គម្ចាស់និងម្ចាស់ក្សត្រីខ្មែរ ដែលពួកយួនបានចា
ប់យកទៅឃុំឃាំង ត្រូវប្តូរគ្នានឹងពួកឈ្លើយសង្គ្រាម ទាហានហើយនិងនាយទាហា
នយួន ដែលខ្មែរចាប់បាន ។ រួចហើយពួកគេបានបិទអង្គប្រជុំ ។

«គឺចាប់ផ្តើមពីសន្ធិសញ្ញាសន្តិភាពនេះហើយ (ដែលសៀម-យួនបានចុះហត្ថ
លេខាពីរបីអាទិត្យក្រោយមក) ដែលជនជាតិខ្មែរចាប់ផ្តើមរត់ចេញពីអាណាខេត្ត
ដែលជាតំបន់កូសាំងស៊ីនសព្វថ្ងៃ ដែលពួកយួនបានកាត់យក ទៅធ្វើជាទឹកដីរបស់
ខ្លួនពីសម័យអតីតកាល ។ ហើយទឹកដីដែលពួកខ្មែរទើបបានបោះបង់ ក៏ត្រូវពួកក
សិករយួនចូលមកកាន់កាប់មួយរំពេជ ។ ពួកជនជាតិយួននេះសកម្មណាស់ ជ្រៀត

ជ្រែករុកគួន ចូលចិត្តបង្កជម្លោះ បង្កើតក្តីក្តាំ ហើយយប់ឡើងតែងតែដើរក្រវែលតាមភូមិខ្មែរ  ជាហេតុឲ្យជនជាតិខ្មែរពិបាករស់នៅជាពន់ពេក  ជាប់នឹងភូមិផងរបងជាមួយយួន ។ កាលសម័យនោះ គឺគ្មានយុត្តិធម៌សោះទេចំពោះអតីតម្ចាស់ទឹកម្ចាស់ដី (ជនជាតិខ្មែរ) ហើយការលួចប្លន់រឹបអូសដីស្រែដោយយួនណាម្នាក់ តែងតែបានទទួលតុលាការកាត់សេចក្តីឲ្យឈ្នះជានិច្ចជាកាល ឲ្យតែមានភស្តុតាងបន្តិចបន្តួច ថានៅពេលចុងក្រោយនោះ ជនយួនបានធ្វើចំការដំណាំ ឬបណ្តុះស្រូវពូជនៅទីនោះ ដោយជនជាតិយួនបានជួលដីស្រែក្តី  ឬក៏ជនជាតិយួនបានទៅបណ្តុះដំណាំនៅពេលអវត្តមាននៃម្ចាស់លំនៅក្តី ។ ដីចំការអ្វីក៏ដោយត្រូវចាត់ទុកថា ជាដីបោះបង់ទាំងអស់កាលណាបើជនជាតិយួនចូលទៅនៅ ។ ជួនកាលក៏មានការសងសឹកដ៏កាចសាហាវដែលប្រព្រឹត្តឡើង ៖ មានការដុតផ្ទះ, ឃាតកម្ម, ការទម្លាយភ្លឺស្រែ, ការយកសត្វពាហនៈឲ្យចូលស៊ីដំណាំនៅក្នុងចំការ... ទង្វើទាំងអស់នេះ ក៏បានត្រូវពួកចៅក្រមយួនដាក់ទោសយ៉ាងធ្ងន់ធ្ងរ ។ កាលណាគេរកជនធ្វើកំហុសមិនឃើញទេ (គួរជ្រាបថាក្នុងសម័យនោះ ជនមានទោសមិនដែលត្រូវគេចាប់បានម្នាក់ទេ) គឺភូមិខ្មែរទាំងមូលដែលត្រូវទទួលខុសត្រូវ ។ យួនចាប់មេស្រុក, ពួកឃោក្សាត់ ឬពួកប្រជាជនសាមញ្ញធម្មតា ហើយនៅពេលនោះក៏មានការបង់ផាកពិន័យយ៉ាងហិនហោចខ្លោចផ្សារ, សេចក្តីស្លាប់នៅក្រោមដំបងព្រនង់ ឬរំពាត់ផ្តៅ ហើយជួនកាលក៏មានជម្លោះប្រកាប់ប្រចាក់គ្នា  រវាងក្រុមជនជាតិយួន  និងក្រុមខ្មែរនៅកូសាំងស៊ីន  រួចនៅទីបញ្ចប់ក៏មានការរត់ចេញទាំងហ្វូងទាំងហ្វាយ (ឆ្ពោះទៅកម្ពុជាកណ្តាល) នៃជនជាតិខ្មែរដែលលះបង់ដីធ្លីផ្ទះសំបែងរបស់ខ្លួនទៅឲ្យជនយួន...។ ពួកយួនក៏ចាប់ផ្តើមដាក់ឈ្មោះថ្មីដល់ស្រុកភូមិខ្មែរ និងនៅគ្រប់ទីសង្កាត់ដែលពួកគេបានមកដល់, បំភ្លៃឈ្មោះខ្មែរឲ្យមានសម្លេងផ្សេង រហូតមកដល់ពេលសព្វថ្ងៃនេះ ពួកខ្មែរស្តាប់លែងបាន ។ ជួនជាពេលខ្លះទៀត ពួកគេបានបកប្រែឈ្មោះខ្មែរ ឲ្យទៅជាភាសាយួន ប្រសិនបើឈ្មោះនេះមានអត្ថន័យ ដែលធ្លាប់ស្គាល់កាលពីសម័យមុន ។ ម្ល៉ោះហើយ សំរាប់ជនជាតិខ្មែរដែលជាម្ចាស់ទឹកម្ចាស់ដី សូម្បីតែឈ្មោះភូមិស្រុក ក៏ត្រូវបាត់បង់ផងដែរ ។

«ខេត្តព្រៃនគរ,  នៅពេលដែលយួនចូលមកកាន់កាប់  ក៏បានក្លាយទៅជាខេត្តយ៉ាឌិន ( កកន ៖ តំបន់ព្រៃនគរទូលំទូលាយណាស់ គឺមានសៃគ្កង, ច្រឹឡឹង និងយ៉ាឌិញ) ។ ខេត្តកំពប់ស្រកាត្រី បានក្លាយទៅជាបៀងវ៉ា ។ ខេត្តបារា ទៅជាបារីយ៉ា ។ ផ្សារដែក ទៅជាសាដឹក បន្ទាប់ពីកែឈ្មោះទៅ អាំង-យ៉ាំង ។ ពលលើ ទៅជាបាក់លីវ ។ ទឹកខ្មៅ ទៅជាកាម៉ៅ ។ បាយឆៅ ទៅជាបាយសូវ ។ ពាមមានជ័យ ទៅជា មីថង ។ ស្រុកទ្រាំង ទៅជាសុកត្រាង ។ ពាមមេសែន ទៅជាដូណាង៉ៃ ។ ក្រមួន-ស ទៅជា រ៉ាក់យ៉ា ។ ព្រៃឫស្សី ទៅជា កាន់ថី ។ អូរម៉ោ ទៅជា អុងម៉រ ។ កំពូលមាស ទៅជា ប៊ិញធុយ ។ មាត់ជ្រូក ទៅជា ចូដុក ។ ភ្នំស្វាម ទៅជា នូយសាម ។ បារ៉ាច ទៅជា ឡុងស្វិញ ។ ភ្នំបាជី ទៅជា នូយបាជី ។ ខេត្តមួងខាម ទៅជា ហាទៀង ។ ពាម

(មាត់ជ្រូក) ដែលគេហៅថា មួងខាន ដែរ ក៏បានក្លាយទៅជា ហាទៀង ។ ព្រះត្រពាំង ទៅជា ត្រាយិញ ។ កំពង់ឫស្សី ទៅជា បែនត្រេ ។ លង់ហោរ ទៅជា វិញឡុង ។ មេ-ស ទៅជា មី-ថ ។ កោះកុង ទៅជា ភ្វូកុង ។ កំពង់គោ ទៅជា ទ្រឿងអាន បន្ទាប់មក តាំងអាន ។ បន្លិច ទៅជា បែនលុក ។ រោងដំរី ទៅជា តៃនិញ ។ ភ្នំជើងមេដែង ទៅជា ភ្នំតៃនិញ ដែរ ។ កោះត្រឡាច ទៅជា ពូឡូកុងឱរ ។ កោះត្រល់ ទៅជា ភូកុក ។ ភ្នំយុគ ទៅជា នូយការូសឹ ។ ពាមជើងកាន់ឈើ ទៅជា កាញ់យ៉ (Cap Saint-Jacques) ។ ឈើទាលមួយដើម ទៅជា ធូដូម៉ុត ។ បន្ទាយឫស្សី ទៅជា ហុង-ង្វៀង ។ កំពង់កោះក្របី ទៅជា បែនត្រែ ។ ផ្សារធំ ទៅជា ច្រឹឡឹង (ឈ្មោះចិនដែលមានន័យដូចគ្នា) ។ កង្ហាដាក់ពាង ទៅជា បៀងវ៉ា ។ ដូនណៃ ទៅជា ដុងណាយ ។ កាន់កៅ ទៅជា បាថាក់ (បាសាក់) សព្វថ្ងៃជាសង្កាត់នៃត្រើយខាងស្តាំនៃទន្លេមេគង្គខាងលិច ។ (ដកស្រង់ពីសៀវភៅ Histoire du Cambodge par Adhémard Leclère-pages 434-435-436 ) ។

★

<u>កំណត់សំគាល់</u> ៖ មហារាជចិន បានត្រូវជនជាតិម៉ុងគ្នោលមកកាន់កាប់ត្រួតត្រារាប់រយឆ្នាំ ប៉ុន្តែប្រទេសចិនមិនបានក្លាយទៅជាម៉ុងគោ្លលទេ ។ ចំណែកកម្ពុជាក្រោមដែលមានយួនឈ្លានពាន មកកាន់កាប់តែជាង៣០០ឆ្នាំប៉ុណ្ណោះ ក៏មិនអាចប្រែលក្ខណៈទៅជាយួនដែរ ។ ទឹកដីក្នុងតំបន់នេះ នឹងប្រែក្លាយទៅជាកម្ពុជាក្រោមឡើងវិញក្នុងពេលឆាប់ៗខាងមុខនេះ ។៚

★ ★

★